**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-Mar-2012, 16:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងពាក្យសុំរបស់ នួន ជា**
**ដែលស្នើឲ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹងនាយករដ្ឋមន្ត្រី ហ៊ុន សែន**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**
**ជនជាប់ចោទ:**
នួន ជា
អៀង សារី
ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ:**
សុន អរុណ
Michiel PESTMAN
Victor Koppe
អាង ឧត្តម
Michael G.KARNAVAS
គង់ សំអុន
Anta GUISSÉ
Arthur VERCKEN
Jacques VERGÈS

## I. សេចក្តីផ្តើម និងប្រវត្តិនៃនីតិវិធី

១- កាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១២ មេធាវីការពារក្តីរបស់ នួន ជា ("មេធាវីការពារក្តី" ) បានដាក់ពាក្យសុំមួយ ដើម្បីសុំឲ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹងលោក ហ៊ុន សែន អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ("ពាក្យសុំ" )[1]។ ពាក្យបណ្តឹងនេះបានស្នើទៅអង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") សុំរកឲ្យឃើញថា មានសេចក្តីថ្លែងជាសាធារណៈ របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលទាក់ទងនឹង នួន ជា ("ជនជាប់ចោទ") បានរំលោភទៅលើគោលការណ៍ដែលត្រូវសន្មតជាមុនថាគ្មានទោស ហើយដែលចាត់ទុកថាជាការជ្រៀតជ្រែកមួយចូលទៅក្នុងការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់តុលាការ ។ មេធាវីការពារក្តីបានស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការថ្កោលទោសលោកនាយករដ្ឋមន្ត្រីចំពោះ "ការធ្វើសេចក្តីកត់សំគាល់របស់គាត់ដែលធ្វើឲ្យមានការខូចខាតនេះ"[2] តាមមធ្យោបាយ "ការថ្កោលទោសជាសាធារណៈ public condemnation"[3] ឬ ("ការចាប់ពិរុទ្ធ censure"[4] "ការស្តីបន្ទោស rebuke" [5] និង "ធ្វើការព្រមានជាសាធារណៈ" public warning[6] អនុលោមតាមវិធាន៣៥ នៃវិធានផ្ទៃក្នុង ("វិធាន") ។

២- ពាក្យសុំបច្ចុប្បន្ននេះ មានការធ្វើសំណើផ្ទាល់មាត់ស្រដៀងគ្នានេះមួយតាមក្រោយទៀតដែលដាក់ជូនអង្គជំនុំជម្រះ នាថ្ងៃទី១២ នៃសវនាការ[7] ដែលខ្លឹមសារនៃសំណើផ្ទាល់មាត់នេះ ត្រូវបានលើកឡើងបន្ថែមដោយមេធាវីការពារក្តី ចំនួនពីរដងទៀតក្នុងអម្លុងពេលមួយសប្តាហ៍ក្នុងសវនាការចំនួនពីរថ្ងៃបន្តជាប់គ្នា៖

**ថ្ងៃទី១៨ នៃសវនាការ (ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២)៖**

*ò លោក ម៉ៃខល ផេសមិន៖*

[1] ឯកសារលេខ **E176** *ពាក្យសុំឲ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹង ហ៊ុន សែន អនុលោមតាមវិធាន៣៥ នៃវិធានផ្ទៃក្នុង* ("ពាក្យសុំ"), ចុះថ្ងៃទី២២ កុម្ភៈ ឆ្នាំ២០១២។

[2] ឯកសារលេខ **E176** *ដូចគ្នានឹងខាងលើកន្លែងដដែល* ត្រង់កថាខណ្ឌទី២៣។

[3] ឯកសារលេខ **E176** *ដូចគ្នានឹងខាងលើកន្លែងដដែល*។

[4] ឯកសារលេខ **E176** *ដូចគ្នានឹងខាងលើកន្លែងដដែល*។

[5] ឯកសារលេខ **E176** *ដូចគ្នានឹងខាងលើកន្លែងដដែល* ត្រង់កថាខណ្ឌទី២៤។

[6] ឯកសារលេខ **E176** *ដូចគ្នានឹងខាងលើកន្លែងដដែល*។

[7] ឯកសារលេខ**E1/24.1** ប្រតិចារិក, ចុះថ្ងៃទី១០ មករា ២០១២ ត្រង់ទំព័រ១, បន្ទាត់ទី២៣-២៥។ ទំព័រ២ បន្ទាត់ទី១-១៥។ ទំព័រ៣ បន្ទាត់ទី១ -១៦។

*៧ សូមអរគុណលោកប្រធាន។ ខ្ញុំចង់លើកបន្តទៅលើសំណើដែលយើងបានធ្វើកាលពីសប្តាហ៍មុន*
*៨ ក្រោយពីកំណត់សម្គាល់លើកឡើងដោយនាយករដ្ឋមន្ត្រីជាសាធារណៈអំពីកូនក្តីរបស់ខ្ញុំ។ គាត់ហៅកូន*
*៩ ក្តីរបស់ខ្ញុំថា ជាឃាតក ហើយគាត់លើកឡើងថា សេចក្តីប្រកាសរបស់គាត់នេះគឺជាការលើកឡើងដែល*
*១០ ថាវាជាការថ្កោលទោស។ យើងគិតថា យើងសូមធ្វើការថ្កោលទោសចំពោះសេចក្តីប្រកាសរបស់នាយក*
*១១ រដ្ឋមន្ត្រីនេះ។ ហើយយើងក៏មិនដឹងថា នៅពេលណាដែលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះយើងធ្វើការ*
*១២ សម្រេចទៅលើកូនក្តីរបស់ខ្ញុំ យើងខ្ញុំនៅឡើយទេ។ ដូច្នេះ យើងមិនទាន់ដឹងនៅឡើយ នោះឡើយ។*
*១៣ (ចៅក្រមពិភាក្សាគ្នា)*
*១៤ [១៤:៤៦:៣៥]*
*១៥ **ប្រធានអង្គជំនុំ៖***
*១៦ ឥឡូវជ្រាបឱ្យច្បាស់លាស់ថា អង្គជំនុំជម្រះបានកត់សម្គាល់នូវមតិយោបល់របស់មេធាវីរួចហើយ*
*១៧ ទាំងលើកមុន ហើយទំនងជាមេធាវីបានលើកឡើងនូវបញ្ហាអ្វីក៏ដោយ អង្គជំនុំជម្រះសង្កេតឃើញថា*
*១៨ មេធាវី នួន ជា មេធាវីអន្តរជាតិ នួន ជា ហាក់ដូចជាព្យាយាមក្នុងការនិយាយបញ្ហាដដែលៗប៉ុណ្ណោះ*
*១៩ ហើយបញ្ហានេះ គឺអង្គជំនុំជម្រះមិនធ្វើអត្ថាធិប្បាយអ្វីចំពោះការលើកឡើងរបស់មេធាវី នួន ជា*
*២០ នោះទេ។ ហើយយើងក៏មិនអនុញ្ញាតឱ្យលើកបញ្ហានេះតទៅទៀតរបៀបនេះដែរ*[8]*។*

## ថ្ងៃទី១៩ នៃសវនាការ (ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២)៖

*២១ លោក ម៉ៃខល ផេសមិន៖*
*២២ លោកប្រធាន លោកលោកស្រីចៅក្រមជាទីគោរព ខណៈដែលយើងកំពុងរង់ចាំសាក្សី ខ្ញុំសូម*
*២៣ ឱ្យមានការបញ្ជាក់បំភ្លឺទៅលើមតិយោបល់ដែលលោកប្រធានបានលើកឡើងកាលពីថ្ងៃព្រហស្បតិ៍។ វាគឺ*
*២៤ ជាការផ្លាស់ប្តូរទឡ្ហីករណ៍គ្នាទៅវិញទៅមក ពាក់ព័ន្ធទៅហ្នឹងសេចក្តីប្រកាសដែលធ្វើឡើងដោយនាយក*
*២៥ រដ្ឋមន្ត្រី ហ៊ុន សែន កាលពីពីរសប្តាហ៍មុន ដែលគាត់លើកឡើងអំពីកូនក្តីរបស់ខ្ញុំ ដូចដែលលោកប្រធាន*
*១ បានជ្រាបហើយ គាត់ហៅកូនក្តីខ្ញុំថាជាឃាតកនៃអំពើប្រល័យពូជសាសន៍។ ដូច្នេះហើយខ្ញុំសូមឱ្យ*
*២ តុលាការថ្កោលទោសលោកនាយករដ្ឋមន្ត្រី ហើយបង្គាប់ទៅដល់លោកនាយករដ្ឋមន្ត្រីកុំឱ្យនិយាយដូច្នេះ*
*៣ ទៀតនៅពេលអនាគត។*
*៤ ខ្ញុំបានលើកបញ្ហានេះកាលពីសប្តាហ៍មុនរួចមកហើយ ម្តងទៀត ហើយខ្ញុំបានសួរថា តើនៅពេល*
*៥ ដែលលោកប្រធាន និងលោក លោកស្រី នឹងចេញសេចក្តីសម្រេចទៅលើសំណើរបស់ខ្ញុំ។ លោកប្រធាន*
*៦ បានលើកឡើងថាយើងនឹងមិនធ្វើមតិយោបល់ទៅលើសំណើរបស់លោកនោះទេនៅក្នុងប្រតិចារឹក ហើយ*
*៧ លោកបានរំឭកខ្ញុំថា កុំឱ្យខ្ញុំលើកបញ្ហានេះសាជាថ្មី។*
*៨ ដូច្នេះខ្ញុំសូមឱ្យតុលាការបញ្ជាក់បំភ្លឺទៅលើចំណុចហ្នឹង អ្វីដែលលោកប្រធានប្រកាសថ្ងៃមុននេះ*
*៩ គឺជាសេចក្តីសម្រេចឬក៏យ៉ាងម៉េច ឬក៏លោកប្រធានជម្រាបខ្ញុំថា ឱ្យខ្ញុំទ្រាំបន្តិចទៅ សេចក្តីសម្រេចនឹង*

[8] ឯកសារលេខ **E1/30.1** ប្រតិចារឹក, ថ្ងៃទី១៩ កុម្ភៈ ២០១២, ទំព័រទី១១២, បន្ទាត់ទី ២០-២៥។ ទំព័រទី១១៣ បន្ទាត់ទី១-១២, ទំព័រ ៧៨ (ភាសាខ្មែរ) (សង្កត់ន័យបន្ថែមដោយ*គូសបន្ទាត់ពីក្រោម*)។

*១០ ចេញទាពេលឆាប់ៗ។ ដូច្នេះហើយ ខ្ញុំសូមសួរជាថ្មី ថាតើលោកប្រធាននឹងចេញសេចក្ដីសម្រេចទៅ*

*១១ លើសំណើរបស់ខ្ញុំនេះនៅពេលណាដែរ? សូមបញ្ជាក់។ សូមអរគុណ [9] ។*

៣- នៅក្នុងចម្លើយតបនេះ សហព្រះរាជអាជ្ញា សូមលើកឡើងថា ពាក្យសុំនេះគឺមានលក្ខណៈច្រំដែល ដោយសារតែខ្លឹមសារនៃពាក្យសុំនេះត្រូវបានធ្វើការលើកឡើងដោយអង្គជំនុំជម្រះយ៉ាងគ្រប់គ្រាន់ហើយនៅក្នុងពេលដំណើរការនៃសវនាការ។ ពាក្យសុំនេះចាត់ទុកដូចជាស្មើនឹងការប្ដឹងឧទ្ធរណ៍មួយដែលក្លែងភេទ និងជាការដែលមិនអាចឲ្យទទួលយកនៅចំពោះមុខអង្គជំនុំជម្រះបានឡើយ។ ជាជម្រើសមួយផ្សេងទៀត សហព្រះរាជអាជ្ញា សូមលើកឡើងថា ពាក្យសុំនេះគួរបានបដិសេធចោល ដោយសារវាជាការកត់សម្គាល់របស់លោកនាយករដ្ឋមន្ត្រី: (ក) មិនបានរំលោភទៅលើគោលការណ៍ដែលសន្មតជាមុនថាគ្មានទោសឡើយ។ (ខ) មិនអាចចាត់ទុកថា ជាការជ្រៀតជ្រែកចូលនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការតាមខ្លឹមសារដែលបានចែងក្នុងវិធាន៣៥ បានឡើយ។

## II. ពាក្យសុំនេះមិនអាចឲ្យទទួលយកបានឡើយ

៤- សហព្រះរាជអាជ្ញាសូមជូនសេចក្ដីសន្និដ្ឋានថា អង្គជំនុំជម្រះបានសម្រេចបញ្ចប់រួចហើយនូវខ្លឹមសារនៃពាក្យសុំនេះ ដោយចាត់ទុកថាជាការដាក់ឯកសារដោយច្រំដែលមួយ[10] ឬបណ្ដឹងឧទ្ធរណ៍ដោយក្លែងភេទ។ នៅក្នុងករណីទាំងពីរនេះអង្គជំនុំជំរះមិនគួរទទួលយកនូវពាក្យសុំនេះឡើយ។

៥- ដូចដែលមេធាវីការពារក្ដីបានទទួលស្គាល់[11] អង្គជំនុំជម្រះបានធ្វើការស្ដាប់រួចហើយ និងបានសម្រេចបញ្ចប់លើខ្លឹមសារនៃពាក្យសុំនៅក្នុងពេលដំណើរការសវនាការ នៅថ្ងៃទី២៦នៃសវនាការ ("សេចក្ដីសម្រេចដោយផ្ទាល់មាត់")៖

24 សេចក្ដីសម្រេចលើការជំទាស់របស់មេធាវីការពារក្ដី--មេធាវីអន្តរជាតិការពារក្ដី នួន ជា ទាក់

25 ទិនទៅនឹងការអត្ថាធិប្បាយសាធារណៈអំពីអត្ថិភាពនៃពិរុទ្ធភាពលើកូនក្ដីរបស់ខ្លួន

1 អង្គជំនុំជម្រះកត់សម្គាល់នូវការជំទាស់របស់មេធាវីការពារក្ដី ទៅនឹងសេចក្ដីអត្ថាធិប្បាយ

2 ជាសាធារណៈតាមអត្ថបទសារព័ត៌មាន ដោយបានចោទប្រកាន់ នួន ជា កូនក្ដីរបស់ខ្លួនថាមានពិរុទ្ធភាព

3 ចំពោះឧក្រិដ្ឋកម្មដែលជនជាប់ចោទរូបនេះ កំពុងត្រូវបានជំនុំជម្រះ។

---

[9] ឯកសារលេខ **E1/31.1** ប្រតិចារឹក, ថ្ងៃទី២៣ មករា ២០១២, ទំព័រទី១, បន្ទាត់ទី ២១-២៥ និង ទំព័រទី២, បន្ទាត់ទី ១-១៦, ទំព័រទី ១-២ (ភាសាខ្មែរ)។ (សង្កត់ន័យ បន្ថែមដោយ*គូសបន្ទាត់ពីក្រោម*)។

[10] សូមអានកថាខណ្ឌទី២ ខាងលើ។

[11] ឯកសារលេខ **E176** ពាក្យសុំ, កំណត់សំគាល់លេខ១ *ពីខាងដើម* ត្រង់កថាខណ្ឌទី៧។

អង្គជំនុំជម្រះសាលាដំបូង សូមបញ្ជាក់ថាតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា ជនជាប់ចោទក៏ដោយត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។ ដូច្នេះ ការកំណត់អំពីអត្ថិភាព ឬនត្ថិភាព នៃពិរុទ្ធភាពរបស់ជនជាប់ចោទណាម្នាក់ គឺជា ភារកិច្ចរបស់អង្គជំនុំជម្រះដែលត្រូវសម្រេច -- ដែលនឹងត្រូវសម្រេចនៅពេលបញ្ចប់សវនាការ ដោយផ្អែកលើកិច្ចពិភាក្សាដេញដោលលើអង្គសេចក្តី និងភស្តុតាងនានា ដែលត្រូវបានបង្ហាញនៅក្នុងសវនាការនិងផ្អែកតាមច្បាប់ជាធរមានដែលអនុវត្តនៅ អវតក ប៉ុណ្ណោះ។

[១៥:៥៥:១១]

ដូច្នេះ អង្គជំនុំជម្រះ មិនយកសេចក្តីអត្ថាធិប្បាយសាធារណៈណាមួយពាក់ព័ន្ធនឹងអត្ថិភាព ឬនត្ថិភាពនៃពិរុទ្ធភាពរបស់ជនជាប់ចោទណាម្នាក់ មកពិចារណានៅពេលខ្លួន ពិចារណាចេញសាលក្រមនោះឡើយ[12]។

៦- មេធាវីការពារក្តីបានជំទាស់តវ៉ាចំពោះ *ភាពគ្រប់គ្រាន់* នៃសេចក្តីសម្រេចដោយផ្ទាល់មាត់ ដោយកំណត់លក្ខណៈនៃសេចក្តីសម្រេចនោះថា "មិនមែនជាសេចក្តីសម្រេចទេ"[13] ដោយផ្អែកលើហេតុផលថាៈ (១) ឈ្មោះរបស់លោកនាយករដ្ឋមន្ត្រីមិនត្រូវបានបញ្ជាក់។ (២) លក្ខណៈនៃការចោទប្រកាន់អំពីការរំលោភសិទ្ធិមនុស្សមិនត្រូវបានលើកឡើងបញ្ជាក់។ (៣)យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សនៃអឺរ៉ុប ("ECtHR") ដែលបានលើកមកសំអាងដោយមេធាវីការពារក្តីនោះ មិនត្រូវបានលើកឡើងនោះទេ។ ហើយ (៤) សេចក្តីសម្រេចដោយផ្ទាល់មាត់នោះខ្វះខ្លឹមសារ ដែលគ្មានលើកឡើងពីអ្វីក្រៅពី "និយាយដោយជាក់ស្តែង-ថាអង្គជំនុំជំរះត្រូវមានកាតព្វកិច្ចអនុវត្តតាមរដ្ឋធម្មនុញ្ញ" ហើយមិនអាចកំណត់លក្ខណៈបានត្រឹមត្រូវថា ជាសេចក្តីសម្រេចលើខ្លឹមសារបានឡើយ។[14]

៧- ភាពគ្រប់គ្រាន់នៃសេចក្តីសម្រេចណាមួយនៃអង្គជំនុំជម្រះ គឺជាបញ្ហាមួយដែលតាមត្រឹមត្រូវគឺត្រូវលើកឡើងនៅក្នុងបណ្តឹងសាទុក្ខដែលដាក់ជូនទៅអង្គជំនុំជម្រះតុលាការកំពូលអនុលោមតាមវិធាន១០៤ នៃវិធានផ្ទៃក្នុង ដូចដែលអង្គជំនុំជម្រះបានធ្វើការណែនាំនៅក្នុងអំឡុងពេលនៃដំណើរការសវនាការ ថ្ងៃទី២៨ នៃថ្ងៃសវនាការ (គឺថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១២) នៅពេលដែលសហមេធាវីការពារក្តីបានព្យាយាមលើកឡើងនូវបញ្ហាស្តីពីសេចក្តីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រីជាលើកទី៤ ដែលត្រូវបានដោះស្រាយរួចហើយ៖

[12] ឯកសារលេខ **E1/38.1** ប្រតិចារិក, ចុះថ្ងៃទី២ កុម្ភៈ ២០១២ ត្រង់ទំព័រ១១៣, បន្ទាត់ទី៥-២២, ទំព័រ ៩៤-៩៥ (ភាសាខ្មែរ)។

[13] ឯកសារលេខ **E176** ពាក្យសុំ ត្រង់កថាខណ្ឌទី៧។

[14] ឯកសារលេខ **E176** *ដូចគ្នានឹងខាងលើកន្លែងដដែល*។

*២០ ... ... ...។ ដោយភាពស្មាក់ស្មើរមួយចំនួននោះ  គឺថាយើងត្រូវពិនិត្យឡើងវិញនៅក្នុងការ*
*២១ កត់សម្គាល់ដែលធ្វើឡើងដោយលោកនាយករដ្ឋមន្ត្រី នៅសន្និសីទកាសែតនៅប្រទេសវៀតណាមកន្លងមក --*
*២២ [០៩:១០:២៣]*
*២៣* ***ប្រធានអង្គជំនុំ៖***
*២៤ យើងដូចជាបានប្រាប់អ្នកឯងរួចហើយ ថាអ្នកឯងមិនអាចធ្វើផ្តៀតឱកាសនៅក្នុងការដែលយើង*
*២៥ ផ្តល់ពេលវេលាឲ្យអ្នកឯងសួរទៅកូនក្តីរបស់អ្នកឯង ពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្ត្រទៅលើបញ្ហាផ្សេង*
*១ ទៀតទេ។ ផ្សេងនោះអង្គជំនុំជម្រះបានឆ្លើយតបរួចហើយ អ្វីដែលអង្គជំនុំជម្រះបានសម្រេចរួចហើយ*
*២ ប្រសិនបើអ្នកឯងមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ អ្នកឯងអាចប្តឹងសាទុក្ខទៅតាម*
*៣ នីតិវិធីតុលាការ។ យើងដាច់ខាតមិនឲ្យអ្នកឯងធ្វើអ្វីទៅតាមតែការនឹកឃើញរបស់អ្នកឯងបានទៀត*
*៤ ឡើយ[15] ។*

៨- ហេតុដូចនេះពាក្យសុំខាងលើនេះគឺចាត់ទុកដូចជា បណ្តឹងសាទុក្ខក្លែងភេទមួយនៅក្នុងកាលៈទេសៈដែលសហមេធាវីការពារក្តីចាត់ទុកថាបណ្តឹងសាទុក្ខភ្លាមៗណាមួយ នឹងមិនអាចធ្វើឡើងបានទេ ដូចដែលបានបង្ហាញឲ្យឃើញនៅក្នុងបទអន្តរាគមន៍របស់គាត់ ជាបន្តទៅទៀតនៅចំពោះមុខអង្គជំនុំជំរះនៅក្នុងពេលសវនាការដដែលនេះ៖

*៨* ***លោក ម៉ៃខល ផេសមិន ៖***
*៩ សូមអរគុណលោកប្រធាន។ ខ្ញុំពិតជាមានសំណួរមែនបាទ។ ហើយយើងនឹងសូមប្រកាសថា*
*១០ សេចក្តីសម្រេចទាំងអស់នោះ និងពេលនេះយើងនឹងធ្វើការប្តឹងឧទ្ធរណ៍នៅពេលណាមួយ ឬនៅពេល*
*១១ មានសាលក្រមក្នុងករណីលើករណីនេះ។ ខ្ញុំសូមពន្យល់ដោយសង្ខេបថា យើងប្រកាន់នូវជំហរ*
*១២ ថា សេចក្តីសម្រេចរបស់លោកចៅក្រម គឺថា --*[16]

៩- សហព្រះរាជអាជ្ញា ចាត់ទុកថាវិធាន៣៥នៃវិធានផ្ទៃក្នុងគឺនឹងបង្កើតបានជាមូលដ្ឋានច្បាប់តែមួយគត់សម្រាប់ដោះស្រាយលើសំណើសុំដែលធ្វើឡើងដោយមេធាវីការពារក្តីនៅក្នុងសំណើកាលពីដំបូងរបស់ខ្លួន (“ដើម្បីធ្វើការថ្កោលទោសជាផ្លូវការចំពោះសេចក្តីថ្លែងការណ៍ទាំងនេះ [...] និងស្នើឲ្យលោកនាយករដ្ឋមន្ត្រីឈប់លែងធ្វើសេចក្តីសង្កេតបែបដូចនេះតទៅទៀតនៅក្នុងពេលអនាគត”)[17] ។ វាគឺជាការវែកញែកហេតុផលថា អង្គតុលាការមិនគួរ “ធ្វើការថ្កោលទោស” ចំពោះបុគ្គលណាម្នាក់ដោយគ្មាន

[15] ឯកសារលេខ **E1/40.1** ប្រតិចារឹក, ថ្ងៃទី៨ កុម្ភៈ ២០១២ (ថ្ងៃទី២៨ នៃសវនាការ) ត្រង់ទំព័រទី៣, បន្ទាត់ទី ២០-២៥ និង ត្រង់ទំព័រទី៤, បន្ទាត់ទី ១-៤។ (សង្កត់ន័យបន្ថែមដោយ*គូសបន្ទាត់ពីក្រោម*)។

[16] ឯកសារលេខ **E1/40.1** *ដដែលដូចខាងលើ* ត្រង់ទំព័រទី៤ បន្ទាត់ទី ៨-១២។ (សង្កត់ន័យបន្ថែមដោយ*គូសបន្ទាត់ពីក្រោម*)។

[17] ឯកសារលេខ **E1/24.1** ប្រតិចារិក, ចុះថ្ងៃទី១០ កុម្ភៈ ២០១២ , 10 January 2012 ត្រង់ទំព័រ៣, បន្ទាត់ទី១១-១៤។

មូលដ្ឋានត្រឹមត្រូវតាមច្បាប់ឡើយ។ ហេតុដូចនេះអង្គជំនុំជំរះបានធ្វើ*សេចក្តីសម្រេចរួចហើយ*លើខ្លឹមសារនៃពាក្យសុំ-នោះគឺសំណើសុំធ្វើការថ្កោលទោសអនុលោមតាមវិធាន៣៥ ដែលទាក់ទងនឹងសេចក្តីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រី។

១០- ការបង្កើតឡើងនូវកំណត់ហេតុនៃសវនាការឲ្យបានសមហេតុសមផលបំផុតនោះគឺថា អង្គជំនុំជំរះបានស្តាប់នូវសំណើសុំកាលពីដំបូងរបស់មេធាវីការពារក្តីបានធ្វើការពិភាក្សាគ្នាមួយរយៈ ប្រហែលជា៣សប្តាហ៍ ហើយបានធ្វើសេចក្តីសម្រេចដោយផ្ទាល់មាត់ ដែលសម្រេចបញ្ចប់លើសំណើនោះ ដោយសង្ខេប បញ្ជាក់ជាថ្មីដែលឡើងវិញថា "មិនគួរយកចិត្តទុកដាក់ចំពោះការធ្វើអត្ថាធិប្បាយជាសាធារណៈណាមួយដែលទាក់ទងនឹងពិរុទ្ធភាព ឬភាពស្លូតត្រង់របស់ជនជាប់ចោទណាម្នាក់ក្នុងការឈានទៅដល់ការចេញសាលក្រមរបស់ខ្លួននោះឡើយ"[18] ។ ក្នុងការធ្វើដូច្នេះគឺអង្គជំនុំជម្រះបានបដិសេធមិនព្រមអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការផ្តួចផ្តើមគំនិត ដើម្បីធ្វើកិច្ចស៊ើបសួរអនុលោមតាមវិធាន៣៥ នៃវិធានផ្ទៃក្នុង ដែលបណ្តឹងសាទុក្ខភ្លាមៗ នឹងត្រូវសម្រេចដោយអង្គជំនុំជម្រះតុលាការកំពូលអនុលោមតាមវិធាន ១០៤(៤)(ឃ)។ ថាតើសហមេធាវីការពារក្តីមានការយល់ច្រឡំទៅលើច្បាប់នៅពេលដែលថ្លែងទៅកាន់អង្គជំនុំជម្រះថា គ្មានការធ្វើបណ្តឹងសាទុក្ខភ្លាមៗណាមួយ ដែលកើតចេញពីសេចក្តីសម្រេចដោយផ្ទាល់មាត់ ដែលមិនមានជាប់ទាក់ទងដើម្បីគោលបំណងធ្វើការវាយតំលៃអំពីភាពអាចទទួលយកបាននៃពាក្យសុំនេះឡើយឬយ៉ាងណា?

១១- ផ្អែកលើមូលដ្ឋានខាងលើនេះសហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា ពាក្យសុំនេះមិនអាចឲ្យទទួលយកបានទេ នៅចំពោះមុខអង្គជំនុំជម្រះ។

## III. ពាក្យសុំនេះគួរត្រូវបានបដិសេធចោល

១២- សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានថាសេចក្តីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រី មិនត្រូវបានចាត់ទុកថា ជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ អនុលោមតាម វិធាន ៣៥ នៃវិធានផ្ទៃក្នុង របស់ អវតក នោះឡើយ។

[18] ឯកសារលេខ **E1/38.1** ប្រតិចារិក, ចុះថ្ងៃទី២ កុម្ភៈ ២០១២ , ត្រង់ទំព័រ១១៣, បន្ទាត់ទី២-២២។

១៣-ការទាមទាររបស់មេធាវីការពារក្ដី អំពីការរំលោភលើគោលការណ៍ស្ដីពីសច្ចធានិរទោស ដែលអាចដាក់ទណ្ឌកម្មតាមវិធាន៣៥ ត្រូវផ្អែកដោយផ្នែកខ្លះ ទៅលើការសន្មតថា ចៅក្រម របស់អង្គជំនុំជម្រះ មិនអាចផ្ដាច់ខ្លួនឲ្យនៅតែឯង ដោយសារ "ការគាបសង្កត់....ដើម្បីផ្ដន្ទាទោស"[19] ដែលកើតចេញមកពីសេចក្ដីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រីនោះឡើយ។ សហព្រះរាជអាជ្ញា មិនគាំទ្រចំពោះការសន្មតនៅក្នុងករណីនេះឡើយ។ អង្គជំនុំជម្រះ ដែលមានសមាសភាពសុទ្ធតែចៅក្រមវិជ្ជាជីវៈ បានកែសេចក្ដីយល់ខុសបានយ៉ាងសមរម្យ និងទាំងស្រុងទៅលើគំនិតរបស់ខ្លួន ចំពោះសេចក្ដីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រី តាមរយៈសេចក្ដីសម្រេចផ្ទាល់មាត់របស់ខ្លួន ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១២។

១៤-សំណើផ្ទាល់មាត់បឋម និងការដាក់ពាក្យសុំពេលនេះរបស់ក្រុមមេធាវីការពារក្ដី ផ្អែកលើសេចក្ដីសន្និដ្ឋានថា សេចក្ដីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រីប្រាកដជាបានលើកទឹកចិត្តឲ្យសាធារណជនជឿជាក់ថាជនជាប់ចោទមានពិរុទ្ធភាព[20]។ ត្រង់ចំណុចនេះ មេធាវីការពារក្ដីបានអះអាងដោយសន្មតអំពីទំនាក់ទំនាក់រវាងសេចក្ដីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រី និងមតិសាធារណៈទាក់ទងនឹងពិរុទ្ធភាពរបស់ជនជាប់ចោទ ដើម្បីទាញយកចំណុចស្របគ្នាដោយលើកយករឿងក្ដី *Allenet de Ribemont* តទល់នឹង ប្រទេសបារាំង នៅចំពោះមុខតុលាការ ECtHR ថា៖

> *ដោយពិចារណាលើភាពសមហេតុផលនៅក្នុងរឿងក្ដី Ribemont វាត្រូវតែសន្មតថាផ្នែកជាច្រើននៅក្នុងសង្គមកម្ពុជាបានចាត់ទុកលោក នួន ជា* ថាជាឃាតករ និងជនដែលដល់នៃអំពើប្រល័យពូជសាសន៍ ដោយសារតែលោកនាយករដ្ឋមន្ត្រី បាននិយាយដូចនេះជាសាធារណៈ[21]។

១៥- សហព្រះរាជអាជ្ញា មិនយល់ស្របនឹងការលើកឡើងនេះទេ។ ផលប៉ះពាល់នៃសេចក្ដីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រី ក្នុងបរិបទ ទាក់ទងនឹង អ.វ.ត.ក មានភាពខុសគ្នាជាច្រើនពីរឿងក្ដី *Ribemont* ដោយមានសំអាងហេតុចំនួនបីដូចខាងក្រោម៖

(ក) សេចក្ដីថ្លែងការណ៍ដែលត្រូវបានជំទាស់ក្នុងរឿងក្ដី *Ribemont* ត្រូវបានធ្វើឡើងដោយមន្ត្រីនគរបាលជាន់ខ្ពស់ និងរដ្ឋមន្ត្រី ដែលទាក់ទងទៅនឹងមុខងាររបស់គាត់ដោយផ្ទាល់ ក្នុងអំឡុង

[19] ឯកសារលេខ **E1/24.1** ប្រតិចារិក, ចុះថ្ងៃទី១០ មករា ២០១២, ត្រង់ទំព័រ៣, បន្ទាត់ទី ៤-៥ (ភាសាអង់គ្លេស)។

[20] ឯកសារលេខ **E176** *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌ១៨ ។

[21] ឯកសារលេខ **E176** *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌ១៨ ។

ពេលថ្ងៃដំបូងនៃការស៊ើបអង្កេតឃាតកម្ម[22]។ ចំណែកឯ សេចក្តីថ្លែងការណ៍របស់លោក នាយករដ្ឋមន្ត្រី ត្រូវបានធ្វើឡើងក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីសវនាការ ទាក់ទងនឹងរយៈកាលប្រវត្តិសាស្ត្រដែលជាប់នៅជិតដាមមិនអាចបំភ្លេចនៅក្នុងសង្គមកម្ពុជា ដែលបន្សល់ទុកនូវស្លាកស្នាមផ្ទាល់លើលោកនាយករដ្ឋមន្ត្រី ក៏ដូចជាប្រជាជនកម្ពុជាជាច្រើនដទៃទៀត។ ខុសពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃបារាំង ដែលមានមុខងារគ្រប់គ្រងលើកម្លាំងនគរបាល, លោកនាយករដ្ឋមន្ត្រីមិនមានមុខងារគ្រប់គ្រងលើ អ.វ.ត.ក ឡើយ។ លើសពីនេះ ក្រោយមកទៀត លោកនាយករដ្ឋមន្ត្រី បានលើកឡើងក្នុងសេចក្តីការណ៍របស់គាត់កាលពីថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១២ ដែលលើកឡើងដោយក្រុមមេធាវីការពារក្តីថា "តុលាការចង់ធ្វើអ្វី ក៏ធ្វើទៅ ប៉ុន្តែខ្ញុំមានសិទ្ធិថ្កោលទោសមេដឹកនាំខ្មែរក្រហម"[23] ។

(ខ) សេចក្តីថ្លែងការណ៍នៅក្នុងរឿងក្តី *Ribemont* ត្រូវបានធ្វើឡើងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃបារាំង និងមន្ត្រីនគរបាលជាន់ខ្ពស់ ទៅកាន់សារព័ត៌មានក្នុងស្រុក និងត្រូវបានបោះពុម្ពផ្សាយយ៉ាងទូលំទូលាយ។ ចំណែកឯ សេចក្តីថ្លែងការរបស់លោកនាយករដ្ឋមន្ត្រី ត្រូវបានធ្វើឡើងក្នុងប្រទេសវៀតណាម កាលពីថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១២ ហើយត្រូវបានចុះផ្សាយនៅក្នុងសារព័ត៌មានវៀតណាម[24]។ តាមការពិត ការផ្សព្វផ្សាយនូវសេចក្តីថ្លែងការណ៍នេះឲ្យបានដឹងនៅក្នុងប្រទេសកម្ពុជា ភាគច្រើនផ្អែកលើការខិតខំប្រឹងប្រែងរបស់ក្រុមមេធាវីការពារក្តី។ កាលពីថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ ក្រុមមេធាវីការពារក្តី បានលើកឡើងបញ្ហានេះក្នុងសវនាការសាធារណៈមួយនៃអង្គជំនុំជម្រះ។ មតិយោបល់របស់ក្រុមមេធាវីការពារក្តី ត្រូវបានចុះផ្សាយក្នុងសារព័ត៌មានកម្ពុជាមួយ ដោយផ្អែកលើសេចក្តីរាយការណ៍ព័ត៌មានរបស់AFP[25]។ ជាលទ្ធផលផ្ទាល់នៃយុទ្ធសាស្ត្រដែលបានអនុវត្តដោយក្រុមមេធាវីការពារក្តី សេចក្តីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រី ដែលខ្លួនចាត់ទុកថាជាសេចក្តីថ្លែងការណ៍ "ធ្វើឲ្យខូចខាត"[26]

---

[22] *រឿងក្តី Allenet de Ribemont តទល់នឹង France*, ពាក្យសុំ ECtHR លេខ 15175/89, សាលក្រម ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ ១៩៩៥ ត្រង់កថាខណ្ឌ ៩-១២ (*Ribemont*).។

[23] ឯកសារលេខ **E176** ពាក្យសុំ, កំណត់សំគាល់លេខ១ *ពីខាងដើម* ត្រង់កថាខណ្ឌទី៦។

[24] គេហទំព័រ MySinchew.com, អត្ថបទមានចំណងជើងថា 'Khmer Rouge lawyers slam PM's 'killer' remark', ថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ (ឧបសម្ព័ន្ធ១)។

[25] គេហទំព័រ MySinchew.com, អត្ថបទមានចំណងជើងថា 'Khmer Rouge lawyers slam PM's 'killer' remark', ថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ (ឧបសម្ព័ន្ធ១)។

[26] ឯកសារលេខ **E176** ពាក្យសុំ, កំណត់សំគាល់លេខ១ *ពីខាងដើម* ត្រង់កថាខណ្ឌទី២៣។

ដល់ជនជាប់ចោទ ហើយតម្រូវឲ្យមានសំណងដើម្បីឲ្យមានយុត្តិធម៌[27] ត្រូវបានថ្លែងដដែលៗចំនួនបីលើក និងបានផ្សព្វផ្សាយទូទាំងប្រទេសកម្ពុជាតាមរយៈសារព័ត៌មាន វិទ្យុ និងទូរទស្សន៍។ ការស្នើសុំសំណងចំពោះផលប៉ះពាល់នៃសេចក្តីថ្លែងការណ៍ក្នុងស្ថានភាពនេះ មានភាពវៀចវេរ៖ "អ្នកដែលស្នើសុំភាពយុត្តិធម៌ ត្រូវស្នើដោយស្មោះត្រង់ ឬពាក្យច្បាប់ជាភាសា Roman ថា *ex turpi causa non oritur actio*"[28] ។

(គ) ផ្សេងពីសេចក្តីថ្លែងការណ៍ក្នុង *Ribemont* សេចក្តីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រី មិនអាចត្រូវបានបកស្រាយបានថាជាការខិតខំរបស់"អាជ្ញាធរសាធារណៈ" ដើម្បី "ជូនដំណឹង [...] សារធារណជនអំពីការស៊ើបអង្កេតអំពីឧក្រិដ្ឋកម្មដែលកំពុងធ្វើឡើយ"[29] ។ ទោះបីជាយ៉ាងណា សេចក្តីថ្លែងការណ៍នោះ គ្រាន់តែជាវោហារសាស្ត្រនយោបាយតែប៉ុណ្ណោះ។ ក្នុងករណីបែបនេះ ឥរិយាបទសមរម្យរបស់តុលាការ ត្រូវបានពិពណ៌នាយ៉ាងសមស្របដោយលោកចៅក្រម Frankfurter នៃតុលាការកំពូលរបស់សហរដ្ឋអាមេរិកថា៖

> *ក្នុងពេលមានការប្រឹងប្រែងខាងនយោបាយ ពេលនោះការប៉ុនប៉ងដែលមិនស្មោះត្រង់ ឬដោយគុំគួន ត្រូវបានរៀបចំឡើង* [...] *ហើយត្រូវបានបង្ហាញឲ្យគេជឿ។ តុលាការ មិនមែនជាកន្លែងសម្រាប់ភាពចម្រូងចម្រាស់បែបនេះទេ។ ចុងក្រោយ យើងពឹងផ្អែកលើវន័យរបស់យើងម្នាក់ៗ និងអ្នកបោះឆ្នោត ដើម្បីរារាំងនិងកែប្រែការរំលោភបែបនេះ*[30] ។

១៦- ដោយពិចារណាទៅលើវាក្យស័ព្ទនៃសេចក្តីសម្រេចផ្ទាល់មាត់ សហព្រះរាជអាជ្ញា ធ្វើសេចក្តីសន្និដ្ឋានថា សេចក្តីថ្លែងការរបស់នាយករដ្ឋមន្ត្រី មិនបានស្វែងរក ហើយក៏មិនបានធ្វើឲ្យមានឥទ្ធិពលដល់ចៅក្រមជំនុំជម្រះ នៅក្នុងករណីសំណុំរឿង ០០២/០១ ទេ។ លើសពីនេះទៀត ទង្វើរបស់មេធាវី

---

[27] ឯកសារលេខ **E176** *ដូចគ្នានឹងខាងលើកន្លែងដដែល* ត្រង់កថាខណ្ឌ១៥, ២៣។

[28] អង្គជំនុំជម្រះ អាចយល់ថាខ្លួនមានសិទ្ធិអនុវត្តគោលការណ៍សមធម៌ដែលជាគោលការណ៍ទូទៅនៃច្បាប់។ (សូមមើល រឿងក្តី *River Meuse* "*រឿងក្តី Netherlands តទល់នឹង Belgium*" របាយការណ៍ PCIJ Series A/B No 70 76 ត្រង់ទំព័រ ៧៦ អំពីចៅក្រម Hudson។ *រឿងក្តីទាក់ទងនឹង the Frontier Dispute* "*រឿងក្តី Burkina Faso តទល់នឹង Republic of Mali*" (សាលក្រម) [1986] ICJ Reports 554 at 567-8; *North Sea Continental Shelf cases*, (*រឿងក្តី Federal Republic of Germany តទល់នឹង Denmark*; *រឿងក្តី Federal Republic of Germany តទល់នឹង Netherlands*) [1969] របាយការណ៍លេខ៤ របស់ ICJ ត្រង់ទំព័រ៤៦-៥០។

[29] *Ribemont*, កំណត់សំគាល់លេខ២២ *ពីខាងដើម* ត្រង់កថាខណ្ឌទី៣៨។

[30] *រឿងក្តី Tenney តទល់នឹង Brandhove*, 341 U.S. 367 (1951) ត្រង់ទំព័រ 377-378 (តុលាការកំពូលសហរដ្ឋអាមេរិក)។

ការពារក្តី ចំពោះការផ្សព្វផ្សាយសេចក្តីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រី ពិតជាបានធ្វើឲ្យបែកផ្លាយដោយស្របច្បាប់ដើម្បីបង្កជាមូលហេតុទូទៅ ក្នុងការភ្ជាប់សេចក្តីថ្លែងការណ៍ និងទស្សនៈជាសាធារណៈរបស់ប្រជាជនកម្ពុជា ចំពោះការទទួលខុសត្រូវឧក្រិដ្ឋកម្មរបស់ជនជាប់ចោទ។ ដូច្នេះ អង្គជំនុំជម្រះ មិនគួរអនុវត្តការដាក់ទណ្ឌកម្មយោងតាមវិធាន ៣៥ នោះទេ។

## IV. សំណើ

១៧- យោងតាមសំអាងហេតុខាងលើ សហព្រះរាជអាជ្ញា ស្នើដល់អង្គជំនុំជម្រះសាលាដំបូង៖

(i) សម្រេចមិនទទួលយកពាក្យសុំនេះ ឬក៏ជាជម្រើស

(ii) ច្រានចោលពាក្យសុំនេះទាំងស្រុង៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១២ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Andrew CAYLEY** សហព្រះរាជអាជ្ញា | | [signature] |